ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៥ សហវ.ស.រ.ហ.ល

# សារាចរណែនាំបន្ថែម
# ស្តីពី
# នីតិវិធី នៃការអនុវត្តចំណូលមិនមែនសារពើពន្ធ
# តាមមូលដ្ឋានបង្គរ ជំហានទី១

អនុលោមតាមសារាចរ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និងអនុវត្តតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា២០២១-២០៣១ និងប្រកាសលេខ១៦៦ សហវ.ប្រក អរតន ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃចំណូលមិនមែនសារពើពន្ធ និងប្រកាសលេខ៣៥០ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និង លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ តាមមូលដ្ឋានបង្គរ ដោយត្រូវកត់ត្រាចំណូលបង្គរ និងចំណូលពន្យារ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងដាក់ឱ្យអនុវត្តចំណូលមិនមែនសារពើពន្ធ តាមមូលដ្ឋានបង្គរក្នុងប្រព័ន្ធ NRMIS លើមុខសញ្ញាពីការជួលទ្រព្យសម្បត្តិរដ្ឋ នៅជំហានទី១ ចំនួន ១០ ក្រសួង ស្ថាប័ន រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព្រះបរមរាជវាំង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងការពារជាតិ ក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងយុត្តិធម៌ ព្រមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទ។ ការដាក់ឱ្យអនុវត្តនៅជំហានទី១នេះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- រដ្ឋបាលកណ្តាល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងអនុវត្តចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៤ តទៅ

២- រដ្ឋបាលកណ្តាល នៃក្រសួង ស្ថាប័ន ៩ផ្សេងទៀត រួមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត នឹងអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

ដើម្បីមានមូលដ្ឋានក្នុងការអនុវត្តចំណូលមិនមែនសារពើពន្ធ តាមមូលដ្ឋានបង្គរបានត្រឹមត្រូវ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំបន្ថែមដល់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទខាងលើ អំពីនីតិវិធី និងកិច្ចបញ្ជិកាគណនេយ្យនៃចំណូលមិនមែនសារពើពន្ធ តាមមូលដ្ឋានបង្គរ ដូចខាងក្រោម៖

## ១.ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS)

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ត្រូវប្រើប្រាស់ប្រព័ន្ធ NRMIS ដើម្បីកត់ត្រានិងបង់ចំណូលមិនមែនសារពើពន្ធ និងត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ជូនអតិថិជន ឬ អ្នកជាប់កាតព្វកិច្ចបង់ចំណូល ដើម្បីធ្វើការទូទាត់តាមប្រព័ន្ធទូទាត់អេឡិចត្រូនិក(e-Payment)។ ប្រព័ន្ធ NRMIS នឹងបង្កើតសលាកបត្របង្វែរចំណូលដោយស្វ័យប្រវត្តិ បន្ទាប់ពីវិក្កយបត្រត្រូវបានបង្កើតនិងបញ្ចប់នៅក្នុងប្រព័ន្ធ NRMIS។ ទិន្នន័យសលាកបត្របង្វែរចំណូល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

នឹងត្រូវធ្វើសន្ធានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដោយកត់ត្រាជាចំណូល ថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទ។

**២.កិច្ចបញ្ជិកាគណនេយ្យនៃចំណូលមិនមែនសារពើពន្ធ តាមមូលដ្ឋានបង្គរ**

**ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ**

ឧទាហរណ៍៖ ក្រសួង ឬ ស្ថាប័ន បានចុះកិច្ចសន្យាជួលអគារទំនេរមួយកន្លែងជាមួយក្រុមហ៊ុន ក ដែលមានរយៈពេលនៃការជួល ៥ឆ្នាំ ក្នុងតម្លៃ ៤ ០០០ ០០០រៀល ក្នុងមួយខែ។ កិច្ចសន្យាត្រូវបានចុះហត្ថលេខាដោយភាគីទាំងសងខាង និងមានសុពលភាពចាប់ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ ដែលក្នុងកិច្ចសន្យាតម្រូវឱ្យក្រុមហ៊ុន ក បង់ថ្លៃឈ្នួលប្រចាំខែយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់។ ក្រសួង ឬ ស្ថាប័ន ត្រូវប្រើប្រាស់ប្រព័ន្ធ NRMIS ដើម្បីកំណត់កាលបរិច្ឆេទទូទាត់សម្រាប់ការបង់ថ្លៃឈ្នួលរបស់ក្រុមហ៊ុន ក ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់។ ដូច្នេះ ក្រសួង ឬ ស្ថាប័ន ត្រូវបោះពុម្ពវិក្កយបត្រថ្លៃឈ្នួល នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤ ពីប្រព័ន្ធ NRMIS ជូនទៅក្រុមហ៊ុន ក គឺជាពេលវេលាទទួលស្គាល់ចំណូល។ ក្រសួង ឬ ស្ថាប័ន ត្រូវបោះពុម្ពសលាកបត្របង្វែរចំណូល រួចបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ តាមរយៈប្រព័ន្ធឌីជីថល។ ស្របពេលជាមួយគ្នានេះ ទិន្នន័យសលាកបត្របង្វែរចំណូលដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS នឹងត្រូវធ្វើសន្ធានកម្មមកកាន់ប្រព័ន្ធ FMIS ដោយកត់ត្រាកិច្ចបញ្ជិកាគណនេយ្យដូចខាងក្រោម៖

- ក្រសួង ឬ ស្ថាប័ន បោះពុម្ពសលាកបត្របង្វែរចំណូល នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤

ឥណពន្ធ គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ)(លេខ ១៥០២) ៤ ០០០ ០០០រៀល

ឥណទាន គណនី ការជួលដីនិងអគារ (លេខ ៧៣០៧២) ៤ ០០០ ០០០រៀល

- បន្ទាប់ពីទទួលបានវិក្កយបត្រ ក្រុមហ៊ុន ក បានធ្វើការទូទាត់ថ្លៃឈ្នួលជូនក្រសួង ឬ ស្ថាប័ន តាមប្រព័ន្ធទូទាត់អេឡិចត្រូនិក(e-Payment) នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤។ ក្រោយពីទទួលបានសាច់ប្រាក់ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវកត់ត្រាដូចខាងក្រោម៖

ឥណពន្ធ គណនី ធនាគារ (លេខ ១១.....) ៤ ០០០ ០០០រៀល

ឥណទាន គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ)(លេខ ១៥០២) ៤ ០០០ ០០០រៀល

ឧទាហរណ៍៖ ក្រសួង ខ បានជួលទីតាំងមួយកន្លែងឱ្យធនាគារពាណិជ្ជដៃគូសម្រាប់ដាក់ទូដកសាច់ប្រាក់ដោយស្វ័យប្រវត្តិ (ATM) ដោយទទួលបានប្រាក់ឈ្នួលប្រចាំខែ ចំនួន ១ ០០០ ០០០រៀល មានកិច្ចសន្យាជួលរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដោយតម្រូវឱ្យធនាគារពាណិជ្ជដៃគូ បង់ប្រាក់ឈ្នួលទីតាំងប្រចាំខែ នៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។ បន្ទាប់ពីកិច្ចសន្យាបានចុះហត្ថលេខារវាងភាគីទាំងសងខាងរួចរាល់ ក្រសួង ខ ត្រូវប្រើប្រាស់ប្រព័ន្ធ NRMIS ដើម្បីកត់ត្រា និងកំណត់កាលបរិច្ឆេទទូទាត់ ដោយបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ជូនធនាគារពាណិជ្ជដៃគូ នៅថ្ងៃទី១ នៃសប្តាហ៍ទី១ នៃខែបន្ទាប់ គឺជាពេលវេលាទទួលស្គាល់ចំណូល។ ក្រសួង ខ ត្រូវបោះពុម្ពសលាកបត្របង្វែរចំណូល រួចបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ តាមរយៈប្រព័ន្ធឌីជីថល។ ស្របពេលជាមួយគ្នានេះ ទិន្នន័យសលាកបត្របង្វែរចំណូលដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS នឹងត្រូវធ្វើសន្ធានកម្មមកកាន់ប្រព័ន្ធ FMIS ដោយកត់ត្រាកិច្ចបញ្ជិកាគណនេយ្យដូចខាងក្រោម៖

- ក្រសួង ខ បោះពុម្ពសលាកបត្របង្វែរចំណូល នៅថ្ងៃទី១ នៃសប្តាហ៍ទី១ នៃខែបន្ទាប់

ឥណពន្ធ គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ)(លេខ ១៥០២) ១ ០០០ ០០០រៀល

ឥណទាន គណនី ការជួលអគារ ឬសំណង់ផ្សេងៗ (លេខ ៧៣០៧៣) ១ ០០០ ០០០រៀល

❖ បន្ទាប់ពីទទួលបានវិក្កយបត្រ ដែលធនាគារពាណិជ្ជដៃគូបានធ្វើការទូទាត់ថ្លៃឈ្នួលជូនក្រសួង ខ តាមប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) អគ្គនាយកដ្ឋានរតនាគារជាតិត្រូវកត់ត្រាដូចខាងក្រោម៖

ឥណពន្ធ គណនី ធនាគារ (លេខ ១១.......) ១ ០០០ ០០០រៀល

ឥណទាន គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ) (លេខ ១៥០២) ១ ០០០ ០០០រៀល

ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទ ត្រូវរៀបចំសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀត ទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូល ឱ្យអនុវត្តការបង់ចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក តាមរយៈកម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ តាមរយៈកម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ធនាគារពាណិជ្ជដៃគូ មានជាអាទិ៍៖ ធនាគារ អេស៊ីលីដា ភីអ៊ិលស៊ី ធនាគារ កាណាឌីយ៉ា ក.អ និង ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទក្រសួង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-អគ្គនាយកដ្ឋានរតនាគារជាតិ
-អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
-មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ